**សាររបស់លោកបេណេឌិកតូ**
**ជាអគ្គបាលព្រះសហគមន៍ក្រុងរ៉ូម**
**ផ្ញើជូនយុវជន យុវនារីក្នុងពិភពលោកទាំងមូល**
**ក្នុងទិវាសកលទី២៦ របស់យុវវ័យនា ឆ្នាំ ២០១១**

*"ចូរចាក់ឫសនិងកសាងជីវិតលើព្រះគ្រីស្ត ចូររក្សាជំនឿឲ្យបានរឹងប៉ឹង* (កូឡ២,៧)"

ប្អូនៗ ក្មួយជាទីស្រឡាញ់!

ខ្ញុំតែងតែនឹកដល់ទិវាសកលនៃយុវវ័យនៅក្រុងស៊ីដនីនាឆ្នាំ២០០៨ នៅពេលនោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សម្តែងឫទ្ធានុភាពដ៏អស្ចារ្យ នាំឲ្យយើងទាំងប៉ុន្មានដែលមកពីពិភពលោកទាំងមូលរំភើបចិត្តយ៉ាងខ្លាំង ដោយរួបរួមគ្នាជាចិត្តថ្លើមតែមួយ។ ពេលនោះ យើងបានលើកតម្កើងជំនឿរបស់យើងយ៉ាងអស្ចារ្យ។ នៅពេលប្រជុំនោះក៏ដូចនៅពេលប្រជុំឆ្នាំមុនៗដែរ យុវជនយុវនារីជាច្រើន បានទទួលផលយ៉ាងបរិបូណ៌ សម្រាប់ជីវិតរបស់ខ្លួន និងសម្រាប់ព្រះសហគមន៍ទាំងមូលផងដែរ។

ឥឡូវយើងសូមនឹកគិតដល់ទិវាសកលរបស់យុវវ័យ ដែលនឹងប្រព្រឹត្តទៅនៅក្រុងម៉ាឌ្រីដ (ប្រទេសអេស្ប៉ាញ) នាខែសីហា ២០១១ ខាងមុខនេះ។ នៅឆ្នាំ១៩៨៩ អង្គប្រជុំយុវជនសកល ស្នាក់នៅមួយរយៈនៅប្រទេសអេស្ប៉ាញម្តងហើយ គឺនៅបូជនិយេសដ្ឋាន សន្តយ៉ាកុប នៅក្រុងកំប៉ូស្តែល។ ប៉ុន្មានខែក្រោយមក ស្រាប់តែជញ្ជាំងដែលញែកទីក្រុងប៊ែរឡាំង នៅប្រទេសអល្លឺម៉ង់ត្រូវរលំ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដ៏សំខាន់។ នៅសម័យឥឡូវប្រជាជននៅទ្វីបអឺរ៉ុប ត្រូវស្វែងរកឫសវប្បធម៌របស់ខ្លួនឡើងវិញជាចាំបាច់ គឺជាវប្បធម៌ដែលមានគ្រីស្តសាសនាជាគ្រឹះ។ ហេតុនេះហើយ យើងណាត់ពេលឲ្យជួបគ្នា នៅក្រុងម៉ាឌ្រីដ ដោយមានប្រធានបទដូចតទៅៈ "*ចូរចាក់ឫស និងកសាងជីវិតលើព្រះគ្រីស្ត ចូររក្សាជំនឿឲ្យបានរឹងប៉ឹង* (កូឡ២,៧)"។

ខ្ញុំសូមអញ្ជើញប្អូនៗ ក្មួយមករួមប្រជុំ ព្រោះប្រជុំនេះមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ព្រះសហគមន៍នៅទ្វីបអឺរ៉ុបផង និងសម្រាប់ព្រះសហគមន៍ទាំងមូលផងដែរ។ ខ្ញុំមានបំណងឲ្យយុវជនទាំងអស់ ទោះជាយុវជនដែលធ្វើជីវិតជឿលើព្រះយេស៊ូគ្រីស្តក្តី ទោះជាយុវជនដែលនៅស្ទាក់ស្ទើ និងនៅមានមន្ទិលសង្ស័យអំពីជំនឿលើព្រះគ្រីស្តក្តី ឬជាយុវជនដែលគ្មានជំនឿលើព្រះអង្គសោះក្តី ឲ្យមានបទពិសោ-ធន៍អំពីព្រះគ្រីស្តក្នុងប្រជុំនេះ ពោលគឺខ្ញុំចង់ឲ្យយុវជនទាំងអស់មានបទពិសោធន៍អំពីព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មថ្មី គង់នៅជាមួយយើង និងស្រឡាញ់យើង។ បទពិសោធន៍នេះ មុខជានឹងមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការរស់នៅរបស់ខ្លួនពុំខាន។

## ១-ដំណើរទៅរកប្រភពនៃសេចក្តីសង្ឃឹម

នៅគ្រប់សម័យ សូម្បីតែសព្វថ្ងៃដែរ យុវជនជាច្រើនមានបំណងយ៉ាងខ្លាំង ចង់ឲ្យមនុស្សមានទំនាក់ទំនងយ៉ាងស្មោះត្រង់និងសាមគ្គីគ្នា។ មានគ្នាជាច្រើនសង្ឃាតចង់កសាងទំនាក់ទំនងដ៏ពិតប្រាកដ

ដោយស្រឡាញ់គ្នាយ៉ាងស្មោះ ចង់កសាងក្រុមគ្រួសារដែលមានចិត្តថ្លើមតែមួយ ចង់ឲ្យខ្លួនបានចិត្តនឹងន ស្ងៀមស្ងាត់ និងរស់នៅដោយសេចក្ដីសុខសាន្តយ៉ាងពិតប្រាកដ។ ដូច្នេះ យុវជនសង្ឃឹមថានឹងមានអនាគតភ្លឺស្វាង ប្រកបដោយសុភមង្គល។

តាមពិត ពេលខ្ញុំនឹកដល់កាលខ្ញុំនៅជាយុវជន ខ្ញុំដឹងច្បាស់ថា យុវជនមិនសូវខ្វល់ខ្វាយអំពីការរស់នៅយ៉ាងនឹងន ស្ងៀមស្ងាត់ និងសេចក្ដីសុខសាន្តប៉ុន្មានទេ។ ការស្វែងរកការងារដែលអាចផ្ដល់ឲ្យការរស់នៅរបស់ខ្លួនបានសេចក្ដីសុខសាន្តនិងនក្តី ពិតជាការសំខាន់ដ៏ចំបាច់មែន។ ប៉ុន្តែ ទោះបីយុវជនខិតខំស្វែងរកការងារក្ដី ក៏គេនៅតែសង្វាតស្វែងរកឧត្ដមគតិដ៏ល្អប្រសើរ យកមកតម្រង់ជីវិតរបស់ខ្លួន។ ពេលខ្ញុំនៅជាយុវជន យើងមិនចង់បង្ហួចជីវិត ដោយរស់នៅតាមរបៀបមនុស្សជំនាន់មុន ដែលមិនចង់កែប្រែអ្វីសោះនោះឡើយ គឺនៅពេលនោះ យើងចង់បានអ្វីៗសុទ្ធតែល្អៗ និងថ្មីៗប្លែកពីមុន គឺយើងចង់ស្វែងរកតម្លៃនៃជីវិតដ៏ប្រសើរ។

តាមពិតនៅជំនាន់នោះ បំណងយើងភ្ជាប់ទៅនឹងសភាពការណ៍នយោបាយ គឺយើងរស់នៅក្នុង របបលទ្ធិផ្ដាច់ការជាតិសង្គមនិយម និងកើតសង្គ្រាមសកលទី២។ ពេលនោះ អំណាចរដ្ឋាភិបាលដូចជាឃុំឃាំងយើង។ ដូច្នេះ នៅពេលនោះយើងមានបំណងចង់រួចខ្លួន ចង់បានសេរីភាព និងចង់ពង្រីកសមត្ថភាពទាំងអស់របស់ខ្លួនក្នុងឋានៈជាមនុស្ស។ ខ្ញុំយល់ឃើញថា យុវជនក្នុងគ្រប់សម័យមានបំណងចង់ស្ទុះចេញផុតពីទំនៀមទម្លាប់ គឺយុវជនសង្វាតចង់បានអ្វីៗដែលពិត ល្អប្រសើរ ជាងការរស់នៅជាធម្មតា ដោយមិនព្រមប្រែអ្វីជាថ្មីឡើយ។ តើយុវជនមានបំណងដូច្នេះ គ្រាន់តែជាការយល់សប្ដិ៍ប៉ុណ្ណោះឬ? នៅពេលពេញវ័យ យុវជនមុខជានឹងភ្លេចសប្ដិ៍នោះហើយមើលទៅ? ទេ! មនុស្សកើតមកដើម្បីស្ទុះស្វែងរកអ្វីដ៏ល្អប្រសើរជានិច្ច ពោលគឺអ្វីដែលមិនស្ថិតនៅក្នុងលោកនេះទេ។ អ្វីៗឯទៀត មិនអាចធ្វើឲ្យចិត្តបានស្កប់ស្កល់ទេ។ សន្តអូហ្គូស្តាំង មានប្រសាសន៍យ៉ាងពិតប្រាកដថា "ចិត្តយើងនៅតែខ្វល់ខ្វាយឥតឈប់ឈរជានិច្ច ទាល់តែសម្រាកនៅក្នុងព្រះជាម្ចាស់ទើបស្កប់ស្កល់"។ បំណងរបស់មនុស្សយើង ចង់បានជីវិតដ៏ប្រសើរជាងពីមុន។ បំណងនេះ ពិតជាសញ្ញាសម្គាល់បញ្ជាក់ថា ព្រះជាម្ចាស់ប្រតិស្ឋានយើង និងដូចជាមានស្លាកស្នាមរបស់ព្រះអង្គចារិកកប់ទុកក្នុងចិត្តយើងដែរ។ ព្រះជាម្ចាស់ជាជីវិត ហេតុនេះហើយបានជាអ្វីៗដែលព្រះអង្គប្រតិស្ឋានមក ស្វែងរកចង់បានជីវិត។ ជាពិសេសមនុស្សដែលព្រះអង្គប្រតិស្ឋានឲ្យជារូបតំណាងរបស់ព្រះអង្គ និងឲ្យមានលក្ខណៈដូចព្រះអង្គ ក៏សង្វាតចង់បានសេចក្ដីស្រឡាញ់ ចង់បានអំណរសប្បាយ និងចង់បានសេចក្ដីសុខសាន្ត។

យើងយល់ច្បាស់ថា អ្នកដែលចង់បំបាត់ព្រះជាម្ចាស់ ដោយមានបំណងចង់ឲ្យមនុស្សមានជីវិតរស់រវើក ពិតជាយល់ខុសទាំងស្រុងហើយ ព្រោះព្រះជាម្ចាស់ជាប្រភពនៃជីវិត។ ដូច្នេះអ្នកដែលចង់បំបាត់ព្រះអង្គ ដូចជាផ្ដាច់ខ្លួនពីប្រភពនៃជីវិតនេះ ហើយឃ្លាតឆ្ងាយពីសេចក្ដីពេញលក្ខណៈជាមនុស្ស ព្រមទាំងឃ្លាតឆ្ងាយពីអំណរសប្បាយដ៏ពិតប្រាកដ។ សត្វលោកដែលកើតមក តែឃ្លាតពីព្រះដែលប្រតិស្ឋានខ្លួនមក ពិតជាមានវាសនាសូន្យ។ តាមអរិយធម៌បច្ចុប្បន្ន ក្នុងតំបន់ខ្លះនៅពិភពលោក ជាពិសេសនៅបស្ចឹមប្រទេស មនុស្សជាច្រើនតម្រង់នឹងបំបាត់ព្រះជាម្ចាស់ ចេញពីការរស់នៅរបស់គេ ឬយល់ឃើញថាអ្នកកាន់សាស-

នា គ្រាន់តែ ត្រូវកាន់បែបឯកជន ដោយសាសនាគ្មានទាក់ទិនជាមួយនឹងការរស់នៅក្នុងសង្គម។ ប៉ុន្តែផ្ទុយទៅវិញ អ្វីៗដ៏មានតម្លៃហើយដែលជាគ្រឹះនៃសង្គម ពោលគឺតម្លៃដ៏ថ្លៃថ្នូរនៃជីវិតមនុស្ស តម្លៃនៃសាមគ្គីសាមគ្គា តម្លៃនៃការងារ តម្លៃនៃក្រុមគ្រួសារ សុទ្ធតែហូរចេញមកពីដំណឹងល្អរបស់ព្រះគ្រីស្ត។ យើងយល់ឃើញថា នៅទ្វីបអឺរ៉ុប មនុស្សដូចជាបានបំបាត់ព្រះជាម្ចាស់ហើយ គឺដូចជាលែងចងចាំគ្រីស្តសាសនា ឬបដិសេធគ្រីស្តសាសនាយ៉ាងជាក់ច្បាស់ គឺលះបង់ចោលតម្លៃដ៏ថ្លៃថ្នូរនៃជំនឿលើព្រះគ្រីស្តទៀតផង។ ការលះបង់ដូច្នេះ អាចបណ្តាលឲ្យគេបាត់បង់បុគ្គលិកលក្ខណៈ ដ៏ជ្រៅបំផុតរបស់ខ្លួនផ្ទាល់ដែរ។

ហេតុនេះហើយ បានជាខ្ញុំអញ្ជើញប្អូនៗ ក្មួយយុវជនជាមិត្តសម្លាញ់ឲ្យពង្រឹងដំណើរនៃជំនឿទៅកាន់ព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត។ ប្អូនៗ ក្មួយយុវជនពិតជាអនាគតនៃសង្គម និងពិតជាអនាគតនៃព្រះសហគមន៍ដែរ។ គ្រីស្តទូតប៉ូលតែងសរសេរជូនគ្រីស្តបរិស័ទក្រុងកូឡូសថា គេត្រូវតែមានឫសនិងមានគ្រឹះដ៏មាំ ទើបអាចរស់នៅបានយ៉ាងពេញលេញ។ សេចក្តីនេះ ក៏ពិតប្រាកដមែនសម្រាប់នៅសម័យឥឡូវនេះ គឺជាងនៅសម័យឯទៀតៗទៅទៀត ព្រោះយុវជនជាច្រើន គ្មានគោលដ៏រឹងប៉ឹងយកមកកសាងជីវិតរបស់ខ្លួនទេ បណ្តាលឲ្យគេគ្មានចិត្តនឹងនដែរ។ មនុស្សទូទៅ តែងនឹកគិតថាអ្វីៗក៏ដោយ មានតម្លៃស្មើគ្នា គ្មានសេចក្តីពិត គ្មានគោល ដែលមនុស្សទាំងអស់ត្រូវគោរពគ្រប់គ្នា។ របៀបគិតដូច្នេះ មិនបង្កើតសេរីភាពដ៏ពិតប្រាកដទេ ផ្ទុយទៅវិញបណ្តាលឲ្យមនុស្សម្នាគ្មានចិត្តនឹងន និងសេចក្តីសុខសាន្តក្នុងខ្លួនទេ បណ្តាលឲ្យគេខកចិត្ត និងឲ្យគេបណ្តាយខ្លួនតាមរបៀបគិត និងតាមរបៀបប្រព្រឹត្តរបស់មនុស្សទូទៅនៅសម័យឥឡូវ។

ប្អូនៗ ក្មួយយុវជន! ប្អូនៗ ក្មួយយុវជនមានសិទ្ធិនឹងទទួលគោលជំហរដ៏រឹងប៉ឹង យ៉ាងច្បាស់យកមកជួយក្នុងពេលធ្វើជម្រើសរបស់ខ្លួន និងមកកសាងអនាគតរបស់ខ្លួនទៀត ដូចពន្លកត្រូវការបង្គោលទំរាំខ្លួនចាក់ឫស និងទៅជាដើមឈើមាំមួនអាចបង្កើតផលផ្លែបាន។

## ២- *"ចូរចាក់ឫស និងកសាងជីវិតលើព្រះគ្រីស្ត ចូររក្សាជំនឿឲ្យបានរឹងប៉ឹង"*

ខ្ញុំចង់រិះគិតអំពីពាក្យទាំងបី ដែលគ្រីស្តទូតប៉ូលសរសេរនោះ យកមកពន្យល់អំពីសារៈសំខាន់នៃជំនឿក្នុងការរស់នៅរបស់គ្រីស្តបរិស័ទគឺថា៖ *"ចាក់ឫស" "និងកសាងជីវិតលើព្រះគ្រីស្ត" "រក្សាជំនឿឲ្យបានរឹងប៉ឹង"*។ មាននិមិត្តរូបបីយ៉ាង គឺទីមួយ *"ចាក់ឫស"* នាំឲ្យនឹកដល់ដើមឈើ និងឫសដែលបឺតជីរជាតិមកចិញ្ចឹមដើម។ ទីពីរគឺ *"កសាងជីវិត"* នាំឲ្យនឹកដល់ការសាងសង់ផ្ទះ។ទីបីគឺ *"ឲ្យបានរឹងប៉ឹង"* នាំឲ្យគិតដល់កម្លាំងកាយ កម្លាំងចិត្តគំនិតដែលចម្រើនឡើង។ មុននឹងពន្យល់ពាក្យទាំងបីនេះ ខ្ញុំសូមកត់សម្គាល់ថា កិរិយាស័ព្ទទាំងបីនេះ គឺ*"ចាក់ឫស កសាង រក្សាជំនឿ" សុទ្ធតែជាកិរិយាស័ព្ទ* អសកម្ម តាមវេយ្យាករណ៍ក្រិក។ តាមភាសាដើម *កិរិយាស័ព្ទ* អសកម្មមានន័យថា ព្រះគ្រីស្តផ្ទាល់ជាប្រធាននៃ*កិរិយាស័ព្ទ* គឺព្រះអង្គហើយដែលមានបំណងចង់ចាក់ឫស ចង់កសាង និងចង់ពង្រឹងជំនឿរបស់គ្រីស្តបរិស័ទ។ និមិត្តរូបទីមួយ គឺដើមឈើដែលចាក់ឫសយ៉ាងមាំ ឫសទាំងនោះចិញ្ចឹមដើម ធ្វើឲ្យដើមស្ថិតស្ថេរនឹងន និងបានរឹងប៉ឹង។ បើគ្មានឫស ខ្យល់បក់បោកមក មុខជានឹងរលំដើមឈើ ហើយវាក៏ក្រៀមស្វិតទៅ។ ខ្ញុំសូមសួរថា តើយើង

មានចាក់ឫសណាខ្លះ? យើងមានឪពុកម្ដាយ មានក្រុមគ្រួសារ មានអរិយធម៌ប្រទេសយើង ដែលសុទ្ធតែជាឫសដ៏មានសារៈសំខាន់ ក្នុងបុគ្គលិកលក្ខណៈរបស់យើងមែន។ ព្រះគម្ពីរសម្ដែងឫសមួយទៀត គឺព្យាការីយេរេមីថ្លែងថា៖ "អ្នកដែលផ្ញើជីវិតលើព្រះអម្ចាស់ និងយកព្រះអង្គធ្វើជាបង្អែក ពិតជាទទួលព្រះពរមិនខាន! អ្នកនោះប្រៀបបាននឹងដើមឈើដុះនៅក្បែរផ្លូវទឹក ដែលមានឫសចាក់ទៅរកទឹកហូរ គឺវាមិនខ្លាចកម្ដៅហើយស្លឹករបស់វានៅខៀវខ្ចីជានិច្ច។ នៅពេលរាំងស្ងួត វាមិនព្រួយបារម្ភអ្វីទេ គឺវានៅតែបង្កើតផ្លែផ្កាដដែល។ (យរ ១៧,៧.៨)។

ព្យាការីយេរេមីយល់ឃើញថាពាក្យ "ចាក់ឫស" មានន័យថា ផ្ញើជីវិតលើព្រះអម្ចាស់ទាំងទុកចិត្តជឿលើព្រះអង្គ។ យើងយោងជីវិតពីព្រះជាម្ចាស់មក។ ក្រៅពីព្រះអង្គ យើងមិនអាចរស់នៅយ៉ាងពិតប្រាកដបានទេ។ "ព្រះជាម្ចាស់បានប្រទានព្រះជន្មផ្ទាល់របស់ព្រះអង្គមកយើង ហើយព្រះជន្មនេះស្ថិតនៅក្នុងព្រះបុត្រារបស់ព្រះអង្គ" (១យហ ៥,១១)។ ព្រះយេស៊ូផ្ទាល់បង្ហាញព្រះអង្គទុកជាជីវិតរបស់យើង (យហ ១៤,៦)។ ហេតុនេះហើយ គ្រីស្តបរិស័ទមិនគ្រាន់តែជាអ្នកជឿសេចក្ដីពិតមួយចំនួនទេ តែជាអ្នកមានទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះយេស៊ូគ្រីស្ត ជាអ្នកជួបព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលផ្ដល់ឲ្យខ្លួនមានជីវិតរស់រវើកដោយមានកម្លាំងថ្មី។ នៅពេលយើងមានទំនាក់ទំនងជាមួយព្រះគ្រីស្ត ព្រះអង្គសម្ដែងបុគ្គលិកលក្ខណៈរបស់យើងផ្ទាល់។ ពេលនោះជីវិតយើងក៏ចម្រើនឡើង និងបានពេញលក្ខណៈដោយយើងបានចងមិត្តភាពជាមួយព្រះអង្គ។

ជួនកាលនៅពេលយុវវ័យ ម្នាក់ៗសួរខ្លួនឯងថា តើជីវិតខ្ញុំមានអត្ថន័យយ៉ាងណា? តើខ្ញុំមានបំណងចង់តម្រង់ជីវិតខ្ញុំទៅរកទិសណា? យុវវ័យពិតជាដំណាក់កាលជាគ្រឹះនៃជីវិតមនុស្ស។ ជួនកាលសំណួរទាំងនោះ បណ្ដាលឲ្យខ្លួនព្រួយបារម្ភយ៉ាងយូរ។ យុវជននឹកគិតដល់ការងារដែលខ្លួនចង់ធ្វើនៅពេលអនាគតផង នឹកគិតដល់ទំនាក់ទំនងក្នុងសង្គមដែលខ្លួនត្រូវចងផង នឹកគិតដល់មនោសញ្ចេតនាខាងផ្លូវចិត្តផង ។ល។ ពេលខ្ញុំសរសេរសេចក្ដីនេះ ខ្ញុំនឹករឭកថា ពេលខ្ញុំនៅយុវជន ម៉្យាងខ្ញុំដឹងខ្លួនថា ព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំទៅជាបូជាចារ្យ ប៉ុន្តែបន្ទាប់មក គឺក្រោយសង្គ្រាមសកលទី២ នៅពេលខ្ញុំរៀននៅទេវវិទ្យាល័យនិងនៅមហាវិទ្យាល័យ ខ្ញុំត្រូវតែបញ្ជាក់សេចក្ដីនេះឲ្យបានច្បាស់។ ខ្ញុំតែងសួរខ្លួនឯងថាតើព្រះអម្ចាស់ ពិតជាហៅខ្ញុំឲ្យទៅជាបូជាចារ្យមែនឬយ៉ាងណា? តើព្រះអង្គមានគម្រោងការឲ្យខ្ញុំទៅជាបូជាចារ្យពិតឬយ៉ាងណា? តើខ្ញុំមានសមត្ថភាពអាចមានចិត្តភក្ដី ស្មោះត្រង់នឹងព្រះអង្គជានិច្ច ឬយ៉ាងណា? តើខ្ញុំអាច បម្រើព្រះអង្គដោយអស់ពីចិត្តបាន ឬយ៉ាងណា? ខ្ញុំសម្រេចចិត្តទៅជាបូជាចារ្យមិនមែនដោយស្រួលទេ គឺ ទាំងកើតទុក្ខមែន។ គ្មាននរណាអាចជ្រើសរើសអ្វីមួយដោយមិនកើតទុក្ខទេ ព្រោះខ្លួនត្រូវលះបង់អ្វីៗទាំងអស់ ផ្សេងពីអ្វីដែលយើងបានជ្រើសរើសនោះ។ ប៉ុន្តែក្រោយមក ពន្លឺលេចចេញមក ហើយខ្ញុំជឿជាក់ថា ព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំថ្វាយខ្លួនទៅព្រះអង្គមែន។ ព្រះអង្គមុខជានឹងប្រទានកម្លាំងឲ្យខ្ញុំពុំខាន។ ប្រសិនបើខ្ញុំស្ដាប់ព្រះអង្គ ធ្វើដំណើររួមជាមួយព្រះអង្គ ខ្ញុំពិតជាស្គាល់ខ្លួនខ្ញុំផ្ទាល់។ ការសំខាន់គឺខ្ញុំមិនចង់ ធ្វើតាមបំណងរបស់ខ្លួនផ្ទាល់ តែធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គវិញ ទើបការរស់នៅរបស់ខ្លួនមានអត្ថន័យពិតប្រាកដផង។

ដើមឈើមានឫសធ្វើឲ្យដើមភ្ជាប់យ៉ាងមាំមួននឹងដីយ៉ាងណា គ្រឹះក៏ធ្វើឲ្យផ្ទះនៅស្ថិតស្ថេរជាយូរយ៉ាងនោះដែរ។ យើង *"ចាក់គ្រឹះលើព្រះគ្រីស្ត"* ដោយផ្ញើជីវិតជឿលើព្រះអង្គ (កូឡ២,៦) យើងដូចផ្ទះសាងសង់លើគ្រឹះដូច្នេះដែរ។ តាមប្រវត្តិសាស្ត្រដ៏វិសុទ្ធ មានឧទាហរណ៍របស់សន្តបុគ្គលជាច្រើន ដែលកសាងជីវិតរបស់ខ្លួនលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាគ្រឹះ។ លោកអាប្រាហាំសាងសង់ជីវិតរបស់ខ្លួនលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាគ្រឹះមុនគេបង្អស់។ លោកជាបុព្វបុរសខាងជំនឿធ្វើតាមព្រះបញ្ជារបស់ព្រះជាម្ចាស់ ដែលសូមឲ្យចាកចេញពីក្រុមគ្រួសារ ឪពុករបស់លោក ចេញដំណើរឆ្ពោះទៅទឹកដីដែលលោកមិនស្គាល់។ "លោកអាប្រាហាំផ្ញើជីវិតជឿលើព្រះជាម្ចាស់ ហើយព្រះអង្គប្រោសលោកឲ្យបានសុចរិត ដោយឈ្វេងយល់ដល់ជំនឿនេះ លោកក៏ទទួលឈ្មោះថាជា "មិត្តសម្លាញ់របស់ព្រះអង្គ" ថែមទៀត (យក ២,២៣)។ អស់អ្នកដែលយកព្រះគ្រីស្តជាគ្រឹះនៃជីវិត តែងតបឆ្លើយនឹងព្រះជាម្ចាស់ត្រាស់ហៅគេ គឺអ្នកទាំងនោះផ្ញើជីវិតជឿលើព្រះអង្គ និងប្រតិបត្តិតាមព្រះបន្ទូលព្រះអង្គដែរ។ ព្រះយេស៊ូប្រៀនប្រដៅក្រុមសាវ័កថា៖ "ហេតុអ្វីបានជាអ្នករាល់គ្នាហៅខ្ញុំថា "ព្រះអម្ចាស់!ព្រះអម្ចាស់!" តែមិនប្រព្រឹត្តតាមពាក្យខ្ញុំដូច្នេះ?" (លក ៦,៤៦)។ ពេលនោះព្រះអង្គយកនិមិត្តរូបអំពីផ្ទះមកបញ្ជាក់ថា៖ "អ្នកដែលមករកខ្ញុំ ស្ដាប់ពាក្យខ្ញុំហើយប្រព្រឹត្តតាមខ្ញុំ ខ្ញុំបង្ហាញប្រាប់ឲ្យអ្នករាល់គ្នាដឹងថា គេប្រៀបបានទៅនឹងមនុស្សប្រភេទណា គឺអ្នកនោះប្រៀបបាននឹងមនុស្សម្នាក់ដែលសង់ផ្ទះ។ គាត់ជីកដីយ៉ាងជ្រៅ ហើយចាក់គ្រឹះលើផ្ទាំងថ្ម លុះទឹកជំនន់មកដល់ ទោះបីទឹកហូរមកប៉ះយ៉ាងណាក៏ដោយ ក៏មិនអាចធ្វើឲ្យផ្ទះនោះរង្គើបានដែរ ព្រោះគាត់បានសង់យ៉ាងមាំ។ ចំណែកឯអ្នកដែលស្ដាប់ពាក្យខ្ញុំ តែមិនប្រព្រឹត្តតាម ប្រៀបបាននឹងមនុស្សម្នាក់ដែលសង់ផ្ទះដោយពុំបានចាក់គ្រឹះ។ លុះទឹកហូរបក់មក ផ្ទះនោះក៏រលំខូចខាតភ្លាមគ្មានអ្វីសល់ឡើយ" (លក ៦,៤៦.៤៩)។

យុវជនជាមិត្តសម្លាញ់ ចូរសង់ផ្ទះរបស់ខ្លួនលើផ្ទាំងថ្មដូចអ្នកនោះដែលជីកដីយ៉ាងជ្រៅ។ ចូរប្អូនៗក្មួយខិតខំតាមព្រះបន្ទូលរបស់ព្រះគ្រីស្តជារៀងរាល់ថ្ងៃ ចូរស្ដាប់ព្រះអង្គដូចស្ដាប់មិត្តសម្លាញ់ដ៏ពិតប្រាកដម្នាក់ ដែលរួមដំណើរជាមួយដូច្នេះដែរ។ បើព្រះអង្គគង់នៅក្បែរប្អូនៗ ក្មួយ នោះប្អូនៗ ក្មួយពិតជានឹងមានចិត្តក្លាហានអាចប្រឈមមុខនឹងឧបសគ្គនានា បញ្ហានានា ការខកចិត្ត និងបរាជ័យដោយចិត្តសង្ឃឹម។ ជារឿយៗ សង្គមមនុស្សតែងតែហុចឲ្យប្អូនៗ ក្មួយអាចដោះស្រាយបញ្ហាទាំងនោះតាមរបៀបផ្សេង ហើយស្រួលជាង ក៏ប៉ុន្តែប្អូនៗ ក្មួយដឹងខ្លួនថា របៀបដោះស្រាយទាំងនោះសុទ្ធតែបញ្ឆោតចិត្តប្អូនៗ ក្មួយ មិនផ្ដល់ឲ្យចិត្តបាននឹងន ហើយក៏មិនផ្ដល់អំណរសប្បាយដែរ។ មានតែព្រះបន្ទូលព្រះជាម្ចាស់ប៉ុណ្ណោះទេ ដែលបង្ហាញមាគ៌ាដ៏ពិតប្រាកដ មានតែជំនឿដែលយើងបានទទួលប៉ុណ្ណោះទេ ជាពន្លឺបំភ្លឺ ដំណើរជីវិតយើង។ ចូរទទួលព្រះអំណោយទានខាងវិញ្ញាណនេះទាំងអរព្រះគុណ គឺប្អូនៗ ក្មួយបានទទួលអំណោយទាននេះពីក្រុមគ្រួសារ ចូរសម្រេចចិត្តតបឆ្លើយនឹងព្រះជាម្ចាស់ដែលត្រាស់ហៅប្អូនៗ ក្មួយក្នុងឋានៈជាអ្នកទទួលខុសត្រូវ និងទៅជាមនុស្សពេញវ័យខាងជំនឿ។ កុំជឿអស់អ្នកដែលប្រាប់ថាប្អូនៗ ក្មួយមិនត្រូវការអ្នកដទៃដើម្បីកសាងជីវិតឡើយ។ ផ្ទុយទៅវិញចូរពឹងផ្អែកលើជំនឿរបស់សាច់ញាតិ លើជំនឿរបស់ព្រះសហគមន៍ សូមអរព្រះគុណព្រះអម្ចាស់ ដោយប្អូនៗ ក្មួយបានទទួលជំនឿនិងដោយបានយកមកធ្វើជាកម្មសិទ្ធរបស់ខ្លួនផ្ទាល់។

## ៣-"ចូររក្សាជំនឿឲ្យបានរឹងប៉ឹង"

*"ចូរចាក់ឫស និងកសាងជីវិតលើព្រះគ្រីស្ត ចូររក្សាជំនឿឲ្យបានរឹងប៉ឹង"* (កូឡ២,៧)។ គ្រីស្តទូតប៉ូល សរសេរលិខិតនេះផ្ញើជូនគ្រីស្តបរិស័ទក្រុងកូឡូស ដើម្បីតបឆ្លើយនឹងសេចក្តីត្រូវការរបស់គេ។ នៅក្រុងកូឡូស អ្នកក្រុងខ្លះប្រកាន់គោលគំនិតតាមអរិយធម៌របស់គេនៅសម័យនោះ ខុសស្រឡះពីជំនឿរបស់ព្រះសហគមន៍ បណ្តាលឲ្យគ្រីស្តបរិស័ទបែរខ្នងពីដំណឹងល្អរបស់ព្រះគ្រីស្ត។

ប្អូនៗ ក្មួយយុវជនដ៏ជាទីស្រឡាញ់! អរិយធម៌សម័យឥឡូវ ក៏ដូចអរិយធម៌នៅក្រុងកូឡូសនាសម័យមុនដែរ គឺមានមនុស្សជាច្រើនប្រកាន់គោលគំនិតម៉្យាង មិនគិតអំពីសាសនាសោះ គេមានបំណងបណ្តេញព្រះជាម្ចាស់ចេញពីការរស់នៅរបស់មនុស្សលោក និងពីសង្គម។ គេមានបំណងចង់បង្កើតស្ថានបរមសុខនៅលើផែនដី ដោយគ្មានព្រះអង្គសោះ។ ក៏ប៉ុន្តែតាមប្រវត្តិស្រាស្ត យើងមានបទពិសោធន៍ថាពិភពលោកដែលគ្មានសាសនា ឬគ្មានព្រះជាម្ចាស់ ក្លាយទៅជាស្ថាននរកទៅវិញ គឺម្នាក់ៗគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ក្រុមគ្រួសារនានាបាក់បែកគ្នា ទាំងមនុស្សទាំងប្រជាជាតិស្អប់គ្នាទៅវិញទៅមក មនុស្សខ្វះសេចក្តីស្រឡាញ់ ខ្វះអំណរសប្បាយ ខ្វះសេចក្តីសង្ឃឹម។ ផ្ទុយទៅវិញនៅកន្លែងណាមានមនុស្សនិងប្រជាជនរស់នៅដោយគោរពសាសនា និងនឹកគិតដល់ព្រះជាម្ចាស់ គោរពប្រណិប័តន៍ព្រះអង្គតាមសេចក្តីពិតនិងស្តាប់ព្រះសូរសៀងព្រះអង្គ នៅកន្លែងនោះ គេសាងសង់អរិយធម៌នៃសេចក្តីស្រឡាញ់ គេនាំគ្នាគោរពកិត្តិយសដ៏ថ្លៃថ្នូររបស់មនុស្សម្នាក់ៗ មនុស្សរួបរួមគ្នាកាន់តែជិតស្និទ្ធឡើងៗ ហើយការរួបរួមគ្នានេះបង្កើតផលល្អជាច្រើន។ ប៉ុន្តែមានគ្រីស្តបរិស័ទខ្លះ បណ្តោយខ្លួនចូលចិត្តតាមគោលគំនិតរបស់មនុស្សដែលចង់ផ្តាច់សាសនាពីសង្គម ឬពេញចិត្តនឹងសាសនាខ្លះដែលណែនាំឲ្យឃ្លាតឆ្ងាយពីជំនឿលើព្រះយេស៊ូគ្រីស្ត ។ មានគ្រីស្តបរិស័ទមួយចំនួនទៀត ទោះបីគេមិនតាមគោលគំនិតទាំងនោះក្តី ក៏បណ្តោយឲ្យជំនឿរបស់គេលើព្រះគ្រីស្តអន់ថយ បណ្តាលឲ្យកើតលទ្ធផលអាក្រក់ ហើយលែងគោរពតាមសីលធម៌ទៀតផង។

គ្រីស្តទូតប៉ូល រំឭកបងប្អូនដែលបណ្តោយខ្លួនតាមគោលគំនិតប្លែកពីដំណឹងល្អទាំងនោះ អំពីឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង។ គម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នេះ ពិតជាគ្រឹះនៃជីវិតរបស់យើង គឺជាស្នូលនៃជំនឿរបស់គ្រីស្តបរិស័ទ។ ទស្សនវិទ្យាទាំងប៉ុន្មានដែលមិនទទួលគម្រោងការដ៏អស្ចារ្យនេះ ចាត់ទុកជំនឿលើព្រះគ្រីស្តថា ជា "ជំនឿលេលា" (១ករ ១,២៣) តែអ្នកកាន់តាមទស្សនវិទ្យាទាំងនោះបង្ហាញឲ្យដឹងថា គេមិនអាចដោះស្រាយសំណួរដ៏សំខាន់ៗ ដែលចោទឡើងក្នុងចិត្តមនុស្សបានឡើយ។ ហេតុនេះហើយ បានជាខ្ញុំ ក្នុងឋានៈជាអ្នកបន្តមុខងាររបស់គ្រីស្តទូតសិលាមក ខ្ញុំក៏ចង់ពង្រឹង *ជំនឿ* ប្អូនៗ ក្មួយ *ឲ្យបានរឹងប៉ឹង*ដែរ (លក ២២,៣២)។ យើងជឿជាក់ថា ព្រះគ្រីស្តយេស៊ូ បានបូជាព្រះជន្មលើឈើឆ្កាង ដើម្បីចែករំលែកព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គឲ្យមនុស្សលោក។ ពេលព្រះអង្គរងទុក្ខលំបាក ព្រះអង្គផ្ទុកអំពើបាបរបស់យើងមកដាក់លើព្រះអង្គ ទ្រង់ធ្វើឲ្យព្រះបិតាលើកលែងទោសឲ្យយើង និងចងសម្ពន្ធមេត្រីជាថ្មីរវាងព្រះបិតា និងមនុស្សយើង ព្រមទាំងប្រោសឲ្យយើងមានផ្លូវទៅកាន់ព្រះជន្មផ្ទាល់របស់ព្រះបិតា។ ដូច្នេះព្រះយេស៊ូរំដោះយើងឲ្យបានរួចពីអ្វីៗ ដែល

រារាំងដំណើរជីវិតរបស់យើង ពោលគឺអំពើបាបដែលបណ្តាលឲ្យយើងទៅជាទាសករ។ ដោយសារព្រះអង្គ យើងអាចស្រឡាញ់មនុស្សទាំងអស់បាន សូម្បីតែខ្មាំងសត្រូវ ក៏យើងអាចស្រឡាញ់បានដែរ ព្រមទាំងចែករំលែកព្រះហឫទ័យស្រឡាញ់នេះដល់បងប្អូនក្រីក្រជាងគេ និងដល់បងប្អូនដែលកើតទុក្ខច្រើនជាងគេផងដែរ។

យុវជនជាទីស្រឡាញ់ ! យើងតែងតែខ្លាចឈើឆ្កាង ហាក់ដូចឈើឆ្កាងនេះ ជាសញ្ញាសម្គាល់នៃការបំផ្លាញជីវិត។ តែផ្ទុយទៅវិញ ឈើឆ្កាងសម្តែងអំពីព្រះហឫទ័យស្រឡាញ់ដែលហួសពីការស្មាន របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក និងជាប្រភពនៃជីវិតដែលផុសឡើង។ ព្រះជន្មរបស់ព្រះបិតា បានផុសចេញ មកពីព្រះបេះដូងព្រះយេស៊ូ ដែលត្រូវគេចាក់ទម្លុះនៅលើឈើឆ្កាង។ ព្រះអង្គសព្វព្រះហឫទ័យប្រទានព្រះជន្មនេះជានិច្ច មកអស់អ្នកដែលសុខចិត្តសម្លឹងមើលព្រះយេស៊ូដែលត្រូវគេឆ្កាងនោះ។ ហេតុនេះខ្ញុំនៅតែអញ្ជើញប្អូនៗ ក្នុងឲ្យទទួលឈើឆ្កាងរបស់ព្រះយេស៊ូ ទុកជាសញ្ញាសម្គាល់សម្តែងអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា និងទុកជាប្រភពនៃជីវិតថ្មី។ ក្រៅពីព្រះគ្រីស្ត ដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿងនេះ គ្មានការសង្គ្រោះផ្សេងទៀតឡើយ! មានតែព្រះគ្រីស្តមួយព្រះអង្គគត់ដែលអាចរំដោះមនុស្សលោកឲ្យបានរួចផុតពីសេចក្តីអាក្រក់! មានតែព្រះគ្រីស្តមួយព្រះអង្គទេ ដែលអាចពង្រីកព្រះរាជ្យនៃយុត្តិធម៌ នៃសន្តិភាព និងនៃសេចក្តីស្រឡាញ់ដែលយើងទាំងអស់គ្នាសង្ឃាតស្វែងរកចង់ បាននោះ។

## ៤-ទោះបីយើងមើលព្រះគ្រីស្តមិនឃើញក្តី ក៏ត្រូវធ្វើជីវិត ជឿលើព្រះគ្រីស្ត

ក្នុងគម្ពីរដំណឹងល្អ មានចែងអំពីបទពិសោធន៍របស់គ្រីស្តទូតថូម៉ា ដែលទទួលគម្រោងការដ៏អស្ចារ្យនៃឈើឆ្កាង គឺអំពីព្រះគ្រីស្តដែលសោយទិវង្គតនិងមានព្រះជន្មថ្មីដ៏រុងរឿង។ លោកថូម៉ាជាគ្រីស្តទូតម្នាក់ក្នុងចំណោមគ្រីស្តទូតទាំងដប់ពីរនាក់។ លោកដើរតាមព្រះយេស៊ូ ឃើញព្រះអង្គប្រោសអ្នកជំងឺឲ្យបានជា និងឃើញព្រះអង្គធ្វើការអស្ចារ្យផ្សេងៗ។ លោកក៏ស្តាប់ព្រះអង្គមានព្រះបន្ទូលដែរ។ ប៉ុន្តែនៅពេលព្រះបរមគ្រូទទួលមរណភាព គាត់ដូចជាវិលវល់ក្នុងចិត្ត។ ល្ងាចបុណ្យចម្លង ពេលព្រះអម្ចាស់សម្តែងព្រះអង្គឲ្យក្រុមសាវ័កឃើញ លោកថូម៉ាមិននៅជាមួយពួកគេទេ។ ពេលក្រុមគ្រីស្តទូតជម្រាបគាត់ថា ព្រះយេស៊ូមានព្រះជន្មគង់នៅ និងសម្តែងព្រះអង្គឲ្យគេឃើញ លោកប្រកាសថា៖ "បើខ្ញុំមិនឃើញស្នាមដែកគោលនៅបាតដៃ និងមិនបានដាក់ម្រាមដៃក្នុងស្នាមដែកគោល ហើយបើខ្ញុំមិនដាក់ដៃត្រង់ឆ្អឹងជំនីរបស់លោកទេ ខ្ញុំមិនជឿជាដាច់ខាត" (យហ២០,២៥)។

យើងក៏ចង់ឃើញព្រះយេស៊ូដែរ ចង់និយាយជាមួយព្រះអង្គ ចង់ដឹងច្បាស់ថាព្រះអង្គគង់នៅជា មួយយើងមែន។ សព្វថ្ងៃ មនុស្សជាច្រើនពិបាកស្គាល់ព្រះយេស៊ូ។ មានគេផ្សាយទស្សនៈអំពីព្រះយេស៊ូតាមគេស្រម័យឃើញ ទាំងអះអាងថា ទស្សនៈទាំងនោះជាវិទ្យាសាស្ត្រ។ ដោយគិតដូច្នេះ គេបំបាត់លក្ខណៈដ៏ ឧត្តុង្គឧត្តមរបស់ព្រះអង្គ ដែលមានតែមួយព្រះអង្គគត់។ ហេតុនេះហើយ បានជាក្រោយពីបានសិក្សានិងស្មឹងស្មាធ៍ធ្វើសម្មាធិជាយូរឆ្នាំ ខ្ញុំមានគំនិតផុសឡើងក្នុងចិត្ត ចង់បញ្ជូនបទពិសោធន៍ខ្លះៗអំពីខ្ញុំ

ជួបព្រះយេស៊ូដោយផ្ទាល់ខ្លួន។ ខ្ញុំបានសរសេរសៀវភៅមួយអំពីព្រះយេស៊ូ។ ដូច្នេះខ្ញុំអាចជួយប្អូនៗក្មួយឲ្យអាចឃើញ អាចស្តាប់ អាចពាល់ព្រះអម្ចាស់បាន ព្រោះព្រះជាម្ចាស់យាងមកជួបមនុស្សយើងដើម្បីសម្តែងឲ្យយើងស្គាល់ព្រះអង្គ ក្នុងអង្គព្រះយេស៊ូជាអម្ចាស់នោះ។

ប្រាំបីថ្ងៃក្រោយមក ពេលព្រះយេស៊ូផ្ទាល់សម្តែងព្រះអង្គឲ្យក្រុមសាវ័កឃើញ ព្រះអង្គមានព្រះបន្ទូលមកគ្រីស្តទូតថូម៉ាថា៖ "ចូរដាក់ម្រាមដៃអ្នកមកបាតដៃខ្ញុំ ចូរដាក់ដៃអ្នកត្រង់ឆ្អឹងជំនីរខ្ញុំ។ ចូរជឿទៅកុំរឹងរូសមិនព្រមជឿឡើយ!" (យហ ២០,២៦.២៧)។ យើងក៏អាចពាល់ព្រះយេស៊ូម៉្យាងដែរ គឺដូចជាដាក់ដៃលើសញ្ញាសម្គាល់ បញ្ជាក់អំពីព្រះយេស៊ូសោយទិវង្គត និងអំពីព្រះអង្គស្រឡាញ់យើង។ នៅពេលយើងទទួលអគ្គសញ្ញានានា ព្រះអង្គគង់នៅក្បែរយើងយ៉ាងពិសេស ព្រះអង្គប្រគល់ព្រះអង្គឲ្យយើង។

យុវជនជាទីស្រឡាញ់! ចូរយកចិត្តទុកដាក់រៀនឲ្យ "ឃើញ" ឲ្យ "ជួប" ព្រះយេស៊ូ។ ក្នុងអគ្គសញ្ញាអរព្រះគុណ ព្រះអង្គគង់នៅក្បែរយើងរហូតដល់ធ្វើជាអាហារសម្រាប់ផ្គត់ផ្គង់យើងឲ្យធ្វើដំណើរ។ ក្នុងអគ្គសញ្ញាលើកលែងទោស ព្រះអង្គសម្តែងព្រះហឫទ័យមេត្តាករុណាឲ្យយើងស្គាល់។ ចូរទទួលស្គាល់វត្តមានរបស់ព្រះយេស៊ូក្នុងជនក្រីក្រ ក្នុងអ្នកជំងឺ ក្នុងបងប្អូនដែលប្រឈមមុខនឹងទុក្ខលំបាក ហើយដែលត្រូវការឲ្យប្អូនៗ ក្មួយជួយ។ ចូរបម្រើព្រះអង្គក្នុងបងប្អូនទាំងនោះទៅ។

ចូរចាប់ផ្តើមនិយាយសន្ទនានឹងព្រះគ្រីស្តដោយផ្ទាល់ខ្លួន តាមជំនឿ។ ចូរនិយាយសន្ទនាឲ្យកាន់តែប្រសើរឡើងៗ។ ចូរខិតខំឲ្យស្គាល់ព្រះគ្រីស្តដោយអានព្រះគម្ពីរ ដោយអានសេចក្តីប្រៀនប្រដៅនៃព្រះសហគមន៍កាតូលិក។ ចូរនិយាយសន្ទនាជាមួយព្រះអង្គដោយអធិដ្ឋាន ចូរផ្ញើជីវិតលើព្រះអង្គ ទុកចិត្តលើព្រះអង្គទៅ! ព្រះអង្គនឹងមិនដែលក្បត់ការទុកចិត្តរបស់ប្អូនៗ ក្មួយទេ! "អ្នកមានជំនឿតាមគ្រីស្តសាសនាជាបឋម ត្រូវផ្ញើជីវិតទាំងស្រុងដោយផ្ទាល់ទៅលើព្រះជាម្ចាស់។ នៅពេលជាមួយគ្នានេះ អ្នកមានជំនឿក៏សុខចិត្តទទួលសេចក្តីពិតទាំងអស់ ដែលព្រះអង្គបានសម្តែងឲ្យមនុស្សលោកស្គាល់"។ ធ្វើដូច្នេះប្អូនៗក្មួយមុខជានឹងមានជំនឿកាន់តែមាំមួននិងពេញលក្ខណៈ មិនអះអាងតែលើមនោសញ្ចេតនាខាងសាសនា ឬលើការប្រៀនប្រដៅ ដែលប្អូនៗ ក្មួយបានទទួលកាលនៅពីនៅក្មេងប៉ុណ្ណោះទេ តែប្អូនៗក្មួយអាចស្គាល់ព្រះជាម្ចាស់ និងអាចរស់នៅដោយសារព្រះអង្គយ៉ាងពិតប្រាកដ ដូចគ្រីស្តទូតថូម៉ាដែលបង្ហាញជំនឿរបស់ខ្លួនថា៖ "ព្រះអង្គពិតជាព្រះអម្ចាស់ និងជាព្រះរបស់ខ្ញុំមែន!"។

## ៥-ជំនឿរបស់ព្រះសហគមន៍ គាំទ្រយើងដើម្បីឲ្យយើងធ្វើជាសាក្សីថ្នាន

ពេលព្រះយេស៊ូមានព្រះបន្ទូលប្រកាសថា៖ "អ្នកជឿ មកពីអ្នកឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះពិតជាមានសុភមង្គលហើយ!" (យហ ២០,២៨) នៅពេលនោះព្រះអង្គនឹកគិតដល់ព្រះសហគមន៍ដែលយកជំនឿរបស់ក្រុមគ្រីស្តទូតធ្វើជាគ្រឹះ គឺពីក្រុមគ្រីស្តទូតជាសាក្សីដែលបានឃើញព្រះអង្គផ្ទាល់នឹងភ្នែក។ យើងយល់ឃើញថា ជំនឿរបស់ខ្លួនផ្ទាល់ចំពោះព្រះគ្រីស្ត កើតមកពីការសន្ទនាជាមួយព្រះអង្គ ប៉ុន្តែជំនឿនេះក៏ភ្ជាប់ជាមួយជំនឿរបស់ព្រះសហគមន៍ដែរ។ យើងមិនមែនជាអ្នកជឿដាច់ឡែកពីគេបានទេ តែដោយសារអគ្គសញ្ញាជ្រមុជទឹក យើងត្រឡប់ទៅជាសមាជិកនៃព្រះសហគមន៍ ជា

មហាគ្រូសាររួចហើយ។ ជំនឿដែលព្រះសហគមន៍ប្រកាសនោះ ផ្តល់ឲ្យជំនឿរបស់ខ្លួនផ្ទាល់បាននឹងននិងមានទីអាងដែរ។ ពេលយើងថ្វាយអភិបូជាជារៀងរាល់ថ្ងៃអាទិត្យ យើងប្រកាសធម៌ជឿ។ ធម៌ជឿនេះការពារយើងកុំឲ្យផ្ញើជីវិតជឿលើព្រះមួយអង្គប្លែកពីព្រះបិតា ដែលព្រះយេស៊ូបានសម្តែងឲ្យយើងស្គាល់។ "អ្នកជឿម្នាក់ៗ ដូចជាកងតូចមួយក្នុងច្រវាក់ដ៏ធំរបស់អស់អ្នកជឿ។ ខ្ញុំអាចផ្ញើជីវិតជឿលើព្រះជាម្ចាស់បានដោយជំនឿអ្នកដទៃជួយគាំទ្រ។ ដោយខ្ញុំផ្ញើជីវិតជឿលើព្រះជាម្ចាស់ ខ្ញុំក៏ជួយគាំទ្រជំនឿរបស់អ្នកឯទៀតៗដែរ"។ សូមអរព្រះគុណព្រះអម្ចាស់ជានិច្ច ដែលព្រះអង្គបានប្រទានព្រះសហគមន៍ឲ្យយើង។ ព្រះសហគមន៍ណែនាំយើងឲ្យចម្រើនឡើងខាងជំនឿ ដោយមានចិត្តនឹងន គឺជំនឿនេះផ្តល់ជីវិតដ៏ពិតប្រាកដឲ្យយើង (យហ ២០,៣១)។

តាមប្រវត្តិសាស្រ្តនៃព្រះសហគមន៍ បណ្តាសន្តបុគ្គលនិងមរណសាក្សីទាំងឡាយ យោងយកម្លាំងនៅជើងឈើឆ្កាងដ៏រុងរឿងរបស់ព្រះគ្រីស្ត។ ដូច្នេះបណ្តាសន្តបុគ្គលនិងមរណសាក្សីទាំងឡាយ អាចមានចិត្តស្មោះ នឹងព្រះជាម្ចាស់ រហូតដល់អាចបូជាជីវិតបាន។ គេយោងយកកម្លាំងក្នុងជំនឿ អាចឈ្នះភាពទន់ខ្សោយរបស់ខ្លួនផ្ទាល់ មកពុះពារឧបសគ្គនានាបាន។ គ្រីស្តទូតយ៉ូហានមានប្រសាសន៍ថា៖ "តើនរណាអាចឈ្នះលោកីយ៍បាន? គឺអ្នកដែលជឿថា ព្រះយេស៊ូពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន" (១យហ ៥,៥)។ ជ័យជម្នះដែលកើតពីជំនឿ គឺជាជ័យជម្នះកើតពីសេចក្តីស្រឡាញ់។ គ្រីស្តបរិស័ទជាច្រើនឥតគណនាផ្តល់សក្ខីភាពកាលពីមុន ហើយមានគេនៅតែផ្តល់សក្ខីភាពឥឡូវនេះទៀត បានរស់នៅដោយសារកម្លាំងនៃជំនឿ ដែលលេចចេញមកពីសេចក្តីស្រឡាញ់ គឺពួកគេយកចិត្តទុកដាក់កសាងសន្តិភាព ខិតខំទាមទារយុត្តិធម៌ក្នុងសង្គម សាងសង់ពិភពលោកប្រកបដោយមនុស្សធម៌ឲ្យកាន់តែប្រសើរឡើងៗ ជាពិភពលោកតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ គេប្តេជ្ញាចិត្តក្នុងគ្រប់វិស័យនៃសង្គម ដោយយកសមត្ថភាពនិងបច្ចេកទេសរបស់ខ្លួន មកជួយដល់ប្រយោជន៍រួមយ៉ាងសកម្ម។ សេចក្តីស្រឡាញ់ដែលផុសចេញពីជំនឿណែនាំគេឲ្យផ្តល់សក្ខីភាពយ៉ាងច្បាស់ ទាំងដោយគេពោលពាក្យសម្តី ទាំងដោយគេប្រព្រឹត្តកិច្ចការ គឺព្រះគ្រីស្តពុំគ្រាន់តែជាសម្បត្តិដ៏ថ្លៃថ្នូរសម្រាប់តែខ្លួនគេប៉ុណ្ណោះទេ តែជាសម្បត្តិដ៏ថ្លៃថ្នូរជាងគេ ដែលយើងត្រូវតែចែករំលែកដល់អ្នកដទៃទៀត។ សម័យឥឡូវជាសម័យមនុស្សលោករួបរួមគ្នា ចូរប្អូនៗ ក្មួយធ្វើជាសាក្សីក្នុងពិភពលោកទាំងមូលទៅ! ចូរធ្វើជាសាក្សីអំពីសេចក្តីសង្ឃឹមរបស់គ្រីស្តបរិស័ទ ក្នុងពិភពលោកទាំងមូល!។ មានមនុស្សជាច្រើនចង់បានសេចក្តីសង្ឃឹមនេះ!។ ពេលព្រះយេស៊ូនៅមុខផ្នូររបស់លោកឡាសារជាមិត្តសម្លាញ់ ដែលចែកឋានបួនថ្ងៃទៅហើយនោះ មុនព្រះអង្គប្រោសឲ្យគាត់មានជីវិតថ្មី ព្រះអង្គមានព្រះបន្ទូលទៅនាងម៉ាថា ថា៖ "បើនាងផ្ញើជីវិត ជឿលើខ្ញុំ នាងមុខជានឹងឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់" (យហ ១១,៤០)។ ប្អូនៗ ក្មួយក៏ដូច្នេះដែរ បើប្អូនៗ ក្មួយផ្ញើជីវិតជឿលើព្រះយេស៊ូ ធ្វើសាក្សីដោយរស់នៅតាមជំនឿជារៀងរាល់ថ្ងៃ ប្អូនៗ ក្មួយក៏មុខជានឹងជួយយុវជនឯទៀតៗ ដូចប្អូនៗ ក្មួយឲ្យរកឃើញអត្ថន័យនៃជីវិត និងបានអំណរដែលកើតមកពីខ្លួនបានជួបព្រះគ្រីស្ត។

## ៦-ចូរនឹកគិតដល់ទិវាសកលនៅក្រុងម៉ាឌ្រីដចុះ

យុវជនជាមិត្តសម្លាញ់! ខ្ញុំសូមអញ្ជើញប្អូនៗ ក្មួយសាជាថ្មី ឲ្យចូលរួមមកទិវាសកលនៃយុវវ័យនៅក្រុងម៉ាឌ្រីដ ខ្ញុំមានអំណរជាពន្លឹករង់ចាំប្អូនៗ ក្មួយម្នាក់ៗផ្ទាល់។ព្រះគ្រីស្តសព្វព្រះហឫទ័យពង្រឹងជំនឿប្អូនៗ ក្មួយដោយសារព្រះសហាគមន៍។ ការជ្រើសរើសធ្វើជីវិតជឿលើព្រះគ្រីស្ត និងរស់នៅតាមព្រះអង្គមិនងាយទេ។ ជួនកាលយើងមិនស្មោះនឹងព្រះអង្គ មានគ្នាជាច្រើនល្បួងយើងឲ្យដើរផ្លូវស្រួលដើរជាង។ ការទាំងនេះ សុទ្ធតែជាឧបសគ្គរាំងដំណើរយើង។ កុំអស់សង្ឃឹមឲ្យសោះ! ផ្ទុយទៅវិញ ចូររកឲ្យសហាគមន៍គ្រីស្តបរិស័ទតាមភូមិភាគមកជួយ គឺព្រះសហាគមន៍តែម្តង! ចូរត្រៀមខ្លួនអស់មួយឆ្នាំយ៉ាងល្អ គឺចូរជួបអភិបាលព្រះសហាគមន៍របស់ប្អូនៗ របស់ក្មួយ ចូរជួបបូជាចារ្យ អ្នកទទួលខុសត្រូវក្នុងការណែនាំយុវជនក្នុងភូមិភាគ ក្នុងសហាគមន៍ ក្នុងភូមិ ក្នុងសមាគម និងក្នុងចលនាផ្សេងៗ។ ប្រសិនបើប្អូនៗ ក្មួយត្រៀមខ្លួនខាងវិញ្ញាណយ៉ាងល្អដោយអធិដ្ឋាន ដោយរួមគ្នាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងដោយគាំទ្រគ្នាទៅវិញទៅមក មុខជាប្រជុំយើងនៅក្រុងម៉ាឌ្រីដខាងមុខនេះបានល្អប្រសើរពុំខាន។

យុវជនជាមិត្តសម្លាញ់! ព្រះសហាគមន៍ពឹងលើប្អូនៗ ក្មួយ! ព្រះសហាគមន៍ត្រូវការជំនឿដ៏រស់រវើករបស់ប្អូនៗ ក្មួយ ត្រូវការសេចក្តីស្រឡាញ់របស់ប្អូនៗ ក្មួយដែលអាចបង្កើតអ្វីច្រើនយ៉ាង ត្រូវការកម្លាំងនិងសេចក្តីសង្ឃឹមរបស់ប្អូនៗ ក្មួយ! វត្តមានរបស់ប្អូនៗ ក្មួយធ្វើឲ្យព្រះសហាគមន៍ប្រែជាថ្មី មិនឲ្យចាស់និងផ្តល់សន្ទុះឡើងយ៉ាងថ្មី។ ហេតុនេះហើយបានជាទិវាសកលនៃយុវវ័យ ជាព្រះអំណោយទានមិនគ្រាន់សម្រាប់តែប្អូនៗក្មួយប៉ុណ្ណោះទេ តែសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូលផងដែរ។ ព្រះសហាគមន៍នៅប្រទេសអេស្ប៉ាញត្រៀមខ្លួនយ៉ាងសកម្មនឹងទទួលប្អូនៗ ក្មួយ និងចាំទទួលបទពិសោធន៍នៃជំនឿយ៉ាងសប្បាយរីករាយរបស់ប្អូនៗ ក្មួយ។ ខ្ញុំសូមអរគុណភូមិភាគព្រះសហាគមន៍តាមភូមិទីសក្ការៈនានា ក្រុមគ្រួសារបព្វជិត បព្វជិតា សមាគម និងចលនានានារបស់ព្រះសហាគមន៍ដែលខិតខំរៀបចំទិវាសកលនេះដោយចិត្តទូលំទូលាយ។ គង់តែព្រះអម្ចាស់នឹងប្រទានពរឲ្យគ្រប់គ្នាពុំខាន។

សូមនាងព្រហ្មចារីម៉ារី ជួយចាត់ចែងដំណើរក្នុងកិច្ចរៀបចំនេះ។ ពេលទេវទូតប្រកាសដំណឹង នាងម៉ារីទទួលព្រះបន្ទូលដោយជំនឿ។នាងសុខចិត្តសហការនឹងព្រះរាជកិច្ចរបស់ព្រះជាម្ចាស់ក្នុងរូបកាយនាង។ ពេលនាងតបឆ្លើយថា "នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ" នាងបានទទួលសេចក្តីស្រឡាញ់យ៉ាងខ្លាំងជំរុញឲ្យនាងថ្វាយខ្លួនទាំងស្រុងលើព្រះអង្គ។

សូមនាងម៉ារីជួយអង្វរព្រះជាម្ចាស់សម្រាប់ប្អូនៗ ក្មួយៗ ដើម្បីឲ្យប្អូនៗ ក្មួយអាចចម្រើនឡើងខាងជំនឿ និងខាងសេចក្តីស្រឡាញ់នៅទិវាសកលខាងមុខនេះ។

ខ្ញុំសូមផ្ញើសួរសុខទុក្ខក្នុងឋានៈជាឪពុកទាំងអធិដ្ឋាន។
ខ្ញុំសូមព្រះជាម្ចាស់ប្រទានពរដល់ប្អូនៗ ដល់ក្មួយៗផង!

ធ្វើនៅបុរីវ៉ាទីកង់ ថ្ងៃទី០៦ សីហា ឆ្នាំ២០១០
ត្រូវនឹងថ្ងៃបុណ្យព្រះអម្ចាស់សម្តែងសិរីរុងរឿង